# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១២ និងលើកទិសដៅ

## ការងារឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ

**ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣**

- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ភ្ញៀវកិត្តិយស សមាជិក សមាជិកា

អង្គសន្និបាតទាំងមូលជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានបិតិសោមនស្សជាអនេក ដោយបានមកចូលរួមជាថ្មីម្តងទៀតក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១២ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ក្នុងឱកាសដ៏ថ្លៃថ្លានេះ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីគ្រប់លំដាប់ថ្នាក់ ទាំងនគរបាលជាតិ រដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានប្រឹងប្រែងបំពេញការងារយ៉ាងសស្រាក់សស្រាំ ពុះពាររួមគ្នាសម្រេចបាននូវសមិទ្ធផលនានាជាច្រើនក្នុងឆ្នាំ២០១២កន្លងទៅនេះ ។

ក្នុងសមិទ្ធផលរួមរបស់ជាតិ នាឆ្នាំ២០១២កន្លងមក យើងទាំងអស់គ្នាពិតជាមានមោទនភាព ដោយបានប្រឹងប្រែងសហការរួមគ្នាជាធ្លុងមួយជុំវិញការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបាននូវសមិទ្ធផលជាប្រវត្តិសាស្ត្រសំខាន់ៗជាអាទិ៍ៈ ការសម្រេចបានដោយជោគជ័យនូវតួនាទីរបស់កម្ពុជាជាប្រធានអាស៊ាន ដែលបានលើកស្ទួយថែមទៀតនូវកិត្យានុភាពរបស់ជាតិយើង និងជាការបង្ហាញច្បាស់អំពីតួនាទីដ៏សកម្មរបស់កម្ពុជាក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនេះ យើងបានរួមគ្នាធានាឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ និងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ឱ្យប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ជាមួយបរិយាកាសសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។

លទ្ធផលនៃការបោះឆ្នោតនេះ គឺជាសមិទ្ធផលនយោបាយ និងសង្គមថ្មីមួយទៀតក្នុងដំណើរការពង្រឹង ពង្រីកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនៅកម្ពុជា។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន អាជ្ញាធរ និងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ឡើងនៃសាទ ការអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដែលគោលនយោបាយ និងវិធានការទាំងនេះ កំពុងទទួលបានការចូលរួម និងការគាំទ្រយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋទូទាំងប្រទេស។

ព្រមជាមួយនេះ ប្រជាជាតិ ប្រជាជនយើងទូទាំងប្រទេស ក៏មានទុក្ខយ៉ាងក្រៀមក្រំចំពោះការសោយទិវង្គតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។ រាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នជាតិ អាជ្ញាធរ មន្ត្រីរាជការ កងកម្លាំងមានសមត្ថកិច្ចគ្រប់ថ្នាក់ ព្រះសង្ឃ ផ្នែកឯកជន និងប្រជាពលរដ្ឋទូទាំងប្រទេស បានរួមសាមគ្គីជាធ្លុងមួយរៀបចំព្រះរាជពិធីបុណ្យថ្វាយព្រះបរមសព ព្រះរាជពិធីដង្ហែរ និង ព្រះរាជពិធីថ្វាយព្រះភ្លើង ព្រះបរមសព **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** យ៉ាងមហោឡារិក អធិកអធម និងមានសុវត្ថិភាពយ៉ាងល្អប្រសើរ ដើម្បីឱ្យសក្តិសមនឹងស្នាព្រះហស្ថ ព្រះកិត្តិយស និង ព្រះកិត្តិនាមរបស់ព្រះអង្គជាព្រះមហាវីរក្សត្រដ៏ឧត្តុង្គឧត្តមនៃប្រជាជាតិ ប្រជាជនយើង។

ព្រឹត្តិការណ៍សំខាន់ៗខាងលើនេះ គឺពិតជាមានការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់ក្រសួងមហាផ្ទៃ ពិសេសគឺកងកម្លាំងនគរបាលជាតិ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានប្រឹងប្រែងមិនខ្លាចនឿយហត់ ក្នុងការរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់បានយ៉ាងល្អប្រសើរសម្រាប់ព្រឹត្តិការណ៍ទាំងនោះ ក៏ដូចជាសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ព្រះរាជពិធីបុណ្យថ្វាយ **ព្រះបរមសព "ព្រះបរមរតនកោដ្ឋ"** ព្រមទាំងខិតខំថែរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសង្គមទាំងមូលបានយ៉ាងគត់មត់។ ជាមួយនេះ ក្រសួងមហាផ្ទៃ ក៏ដូចរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានប្រឹងប្រែងសម្រេចបាននូវសមិទ្ធផលនានាជាច្រើនទៀត រួមទាំងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការធានាឱ្យការងារគ្រប់វិស័យនៅថ្នាក់ក្រោមជាតិមានដំណើរការជាប្រក្រតី។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការធានាឱ្យសង្គមរបស់យើងបន្តរក្សាបានយ៉ាងរឹងមាំនូវសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់យ៉ាងល្អប្រសើរ ជាមួយការសម្រេចបានកំណើនសេដ្ឋកិច្ច៧% ក្នុងឆ្នាំ២០១២កន្លងមកនេះ។ សរុបមក ឆ្នាំ២០១២ កន្លងមកនេះ ចាត់ទុកជាឆ្នាំដ៏មមាញឹក និងជាឆ្នាំដែលបានផ្តល់នូវចំណេះដឹង មេរៀន បទពិសោធន៍ថ្មីៗ ក្នុងការរួបរួមគ្នាលើក

កម្ពស់សមត្ថភាពដឹកនាំ និងភាពជាម្ចាស់ក្នុងការលើកស្ទួយកិត្យានុភាព និងវឌ្ឍនភាពជាតិប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាជាតិ និងប្រជាជនយើង ។

## ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ថ្នាក់ដឹកនាំសំខាន់ៗ ទាំងនគរបាលជាតិ និងរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ព្រមទាំងថ្នាក់ដឹកនាំរាជធានី ខេត្ត ដែលតំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើការពិភាក្សាវាយតម្លៃអំពីសមិទ្ធផលនានាដែលសម្រេចបានក្នុងឆ្នាំ២០១២ ការកំណត់បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងបានឯកភាពគ្នាលើកទិសដៅការងារសម្រាប់អនុវត្តក្នុងឆ្នាំ២០១៣នេះជាបន្តទៀត ។ ក្នុងឱកាសនេះ ខ្ញុំសូមចូលរួមធ្វើការកត់សម្គាល់លើសមិទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

**១**-ឆ្នាំ២០១២ កន្លងទៅនេះ កងកម្លាំងនគរបាលជាតិទូទាំងប្រទេសបានបន្តប្រឹងប្រែងយ៉ាងសស្រាក់សស្រាំក្នុងការរួមចំណែកអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ពិសេសបានខិតខំសម្រេចបានតួនាទីស្នូលក្នុងការរក្សាស្ថិរភាព សន្តិសុខនយោបាយ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ដែលជាបុព្វបទបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ទន្ទឹមនេះ កងកម្លាំងនគរបាលជាតិបានសហការជាមួយកម្លាំងមានសមត្ថកិច្ចនានា រក្សាបានយ៉ាងរឹងមាំនូវសន្តិសុខជាតិ ដោយបង្ក្រាបទប់ស្កាត់មិនឱ្យមានសកម្មភាពភេរវកម្ម សកម្មភាពចលាចល វឹកវរណាមួយក្នុងសង្គមកម្ពុជាយើងឡើយ ។

ជាមួយគ្នានេះ កងកម្លាំងនគរបាលជាតិក៏បានបន្តវីរភាពដ៏អង់អាចក្លាហានក្នុងការសហការជាមួយកងយោធពលខេមរភូមិន្ទ រក្សាការពារយ៉ាងរឹងមាំនូវបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ព្រមទាំងបានបញ្ជូនកម្លាំងចូលទៅទទួលរ៉ាប់រងឈរជើងក្នុងភូមិសាស្ត្រតំបន់គ្មានកងទ័ពបណ្តោះអាសន្ន ជុំវិញប្រាសាទព្រះវិហារ ជំនួសកងយោធពលខេមរភូមិន្ទ ដោយស្មារតីស្នេហាជាតិ និងទទួលខុសត្រូវខ្ពស់ ។

**២**-ក្នុងភារកិច្ចរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ កងកម្លាំងនគរបាលបានលើកកម្ពស់តួនាទីធ្វើជាសេនាធិការជូនគណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ និងជាស្នូលនៃចលនាមហាជន ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដែលកាន់តែទទួលបាននូវការគាំទ្រ និងការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់មជ្ឈដ្ឋាន ជាហេតុធ្វើឱ្យបទល្មើសបានបន្តថយចុះប្រមាណ៦% បើប្រៀបនឹងឆ្នាំមុន ។ ដូច្នេះក្នុងរយៈពេល២ឆ្នាំជាប់ៗគ្នានេះ បទល្មើសមានការថយចុះក្នុងអត្រាពី៦% ទៅ៧% ក្នុងឆ្នាំនីមួយៗ ។

ទន្ទឹមនេះ ការបង្ក្រាបបទល្មើសរបស់កងកម្លាំងនគរបាលជាតិ ក៏មានលទ្ធផលខ្ពស់គួរឱ្យកត់សម្គាល់ ជាពិសេសលទ្ធផលនៃការបង្ក្រាបខ្សែបណ្តាញផលិត ដឹកជញ្ជូនគ្រឿងញៀន ដោយបានធ្វើការបង្ក្រាបចំមេខ្លោងគ្រឿងញៀនធំៗ និងសហការបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មានទ្រង់ទ្រាយធំៗ ដែលមានលក្ខណៈជាប្រព័ន្ធក្នុងតំបន់ ការបង្កាទប់ស្កាត់សកម្មភាពជួញដូរមនុស្ស ព្រមទាំងខិតខំលើកកម្ពស់ការអប់រំ គ្រប់គ្រងក្មេងទំនើង ដើម្បីបង្ការ ទប់ស្កាត់មិនឱ្យកើតឡើងនូវសកម្មភាពរបៀបជាក្រុមសង្គមងងឹតនៅក្នុងសង្គម ។

៣-កងកម្លាំងនគរបាលជាតិបានសហការជាមួយអាជ្ញាធរ និងកម្លាំងមានសមត្ថកិច្ចនានា ប្រឹងប្រែងតស៊ូរៀបចំសណ្តាប់ធ្នាប់ ចរាចរ ដែលជាប្រធានបទមួយមានលក្ខណៈស្មុគស្មាញប្រឈមនឹងទម្លាប់ និងឥរិយាបថចាស់របស់ប្រជាពលរដ្ឋផង និងកំណើនដ៏គំហុកនៃមធ្យោបាយ យានយន្តធ្វើដំណើរគ្រប់ប្រភេទផង ដោយខិតខំធ្វើឱ្យទម្លាប់ និងឥរិយាបថមានការប្រែប្រួលជាវិជ្ជមានជាបណ្តើរៗ និងបានធ្វើឱ្យចំនួនគ្រោះថ្នាក់ចរាចរមានការថយចុះមួយកម្រិត ។ ជាមួយនេះ ស្ថានភាពសណ្តាប់ធ្នាប់ជាទូទៅក្នុងសង្គម ក៏ត្រូវបានរៀបចំជាបន្តបន្ទាប់ ស្របតាមការវិវត្តរីកចម្រើនរបស់ប្រទេសជាតិ ។

៤-ចំពោះកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមហាផ្ទៃបានបន្តសហការ សម្របសម្រួល និងជំរុញដំណើរការកំណែទម្រង់ដ៏សាំញ៉ាំ និងរសើបនេះ ឱ្យបន្តវិវត្តទៅមុខជាជំហានៗ ស្របតាមកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូងនៃកម្មវិធីជាតិនេះ ។ សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០១២កន្លងទៅនេះមានជាអាទិ៍ គឺការបន្តពង្រឹងសមត្ថភាពស្ថាប័នគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ការបណ្តុះបណ្តាល កសាងសមត្ថភាពមន្ត្រីដែលបានដាក់ពង្រាយតាមរចនាសម្ព័ន្ធ និងប្រព័ន្ធថ្មីដែលបានរៀបចំឡើងវិញកាលពីឆ្នាំកន្លងទៅ ការប្រឹងប្រែងសម្របសម្រួល ដើម្បីកសាងរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ ការគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំ រំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការបង្កើតឱ្យមានមូលនិធិក្រុង ស្រុក ព្រមទាំងការគាំទ្រ និងការលើកកម្ពស់សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគម្រោងនានាដែលវិនិយោគដោយធនធានរបស់រាជរដ្ឋាភិបាល ធនធានពីដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធនានា។ ព្រមជាមួយនេះ អាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានប្រឹងប្រែងអនុវត្តយ៉ាងសកម្មនូវគោលនយោបាយ និងវិធានការណ៍នានារបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅមូលដ្ឋាន និងខិតខំសម្របសម្រួល ដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ និងបញ្ហា

ប្រឈមនានានៅមូលដ្ឋាន ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព ។

**៥**-ក្រៅពីសមិទ្ធផលខាងលើនេះ ក្រសួងមហាផ្ទៃក៏បានពុះពារសម្រេចបានសមិទ្ធផលនានាជាច្រើនទៀតដូចជា ការចុះបញ្ជីគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាការងារពន្ធនាគារ ការពង្រឹងកិច្ចសហប្រតិបត្តិការខេត្តជាប់ព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ការចូលរួមដោះស្រាយការងារនានា ក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយក្រសួង ស្ថាប័ននានា ការកសាងច្បាប់ លិខិតបទដ្ឋាន ការចូលរួមក្នុងដំណើរការពង្រឹងលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងប្រព័ន្ធយុត្តិធម៌ក្នុងសង្គម... ។ល ។

## ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ទន្ទឹមនឹងការពុះពារប្រឹងប្រែងសម្រេចបាននូវសមិទ្ធផលនានាជាច្រើន ក៏នៅមានសេសសល់បញ្ហាប្រឈមមួយចំនួនក្នុងក្របខ័ណ្ឌនៃតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ដូចដែលបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍ដែលបានដាក់ឱ្យធ្វើការពិភាក្សាក្នុងអង្គសន្និបាតនេះ ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំគ្រប់ថ្នាក់នៃក្រសួងមហាផ្ទៃ ដែលបានរួមគ្នាធ្វើការពិភាក្សា ស្វះស្វែងរកដំណោះស្រាយជាមួយការបង្កើនថាមភាព ដើម្បីពុះពារជំនះបញ្ហាប្រឈមទាំងនោះ សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់វិស័យក្នុងក្របខ័ណ្ឌ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមធ្វើការគូសបញ្ជាក់អំពីទិសដៅ ភារកិច្ចចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ២០១៣ ដូចខាងក្រោម ÷

ក្នុងឆ្នាំ២០១៣នេះ កម្ពុជាយើងត្រូវបង្កគ្រប់លក្ខណសម្បត្តិ ដើម្បីធានាឱ្យការបោះឆ្នោតជាតិលើកទី៥ ប្រព្រឹត្តទៅប្រកបដោយលក្ខណៈ សេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាស ប្រកបដោយសុខសន្តិភាព ស្ថិរភាពនយោបាយ ដើម្បីបន្តរួមគ្នាពង្រឹងថែមទៀតនូវដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស សំដៅបន្តពង្រឹងស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ប្រកបដោយចីរភាព ។ ម្យ៉ាងទៀត ឆ្នាំ២០១៣នេះ ជាឆ្នាំចុងក្រោយដែលយើងទាំងអស់គ្នាត្រូវពុះពារសម្រេចឱ្យបានដោយជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបន្តជំរុញអនុវត្តឱ្យបានកាន់តែសកម្មថែមទៀតនូវកម្មវិធីកំណែទម្រង់នានា ក្នុងនោះរួមទាំងការកែទម្រង់ឡើនៃសាទ ការអនុវត្តគោលនយោបាយចាស់សកម្មភាព

ថ្មីលើវិស័យឌីជីថល សំដៅធានាឱ្យកម្ពុជាយើងបន្តរក្សាបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ពី ៦,៥% ទៅ ៧% ដើម្បីជាមូលដ្ឋានក្នុងការកាត់បន្ថយភាពក្រីក្រជាបន្តទៀត។ ព្រមជាមួយនេះ យើងនឹងបន្តរួមគ្នាអនុវត្តការងារនានាជាច្រើនទៀត ដើម្បីត្រៀមលក្ខណៈសម្បត្តិឱ្យបានល្អសម្រាប់ការចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នាឆ្នាំ២០១៥ខាងមុខនេះ។

ទន្ទឹមនេះ ក្នុងឆ្នាំ២០១៣នេះ យើងក៏កត់សម្គាល់អំពីបញ្ហាប្រឈមនានាក្នុងតំបន់ និងពិភពលោកនៅតែបន្ត ជាអាទិ៍ ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក មានភាពមិនទៀងទាត់ អាស្រ័យដោយបញ្ហាបំណុលក្នុងប្រទេសមួយចំនួន ការកើនឡើងនៃភាពគ្មានការងារធ្វើ ការធ្លាក់ចុះនូវតម្រូវការប្រើប្រាស់ក្នុងប្រទេសមហាអំណាចសេដ្ឋកិច្ច បញ្ហាភេរវកម្ម ការប្រជែង ឥទ្ធិពលខាងនយោបាយ និងយោធារបស់មហាអំណាចនានា បញ្ហាអាវុធនុយក្លេអ៊ែរ ជម្លោះទឹកដី និងដែនកោះរវាងប្រទេសមួយចំនួនក្នុងតំបន់ ការប្រែប្រួលខាងបរិស្ថាន ។ល។ ដែលបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យយើងខិតខំធ្វើការតាមដានការវិវត្តប្រែប្រួលជាប្រចាំ ដើម្បីមានគោលនយោបាយ និងវិធានការសមស្រប សំដៅបញ្ចៀសផលប៉ះពាល់នៃបញ្ហាប្រឈមទាំងនេះ មកលើកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបាននូវទិសដៅភារកិច្ចរួមរបស់កម្ពុជាយើងនាឆ្នាំ២០១៣នេះ។

ក្នុងន័យនេះ ដើម្បីចូលរួមសម្រេចនូវទិសដៅ ភារកិច្ច ដូចបានគូសបញ្ជាក់ខាងលើ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមផ្តល់អនុសាសន៍ជាគោលនយោបាយ និងគោលការណ៍សំខាន់ៗមួយចំនួនពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដូចខាងក្រោម ÷

**ទីមួយ :** ត្រូវបន្តរួមគ្នារក្សាឱ្យបាននូវសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងខិតខំលើកកម្ពស់ ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ដើម្បីបង្កបរិយាកាសឱ្យការបោះឆ្នោតជាតិលើកទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ខាងមុខនេះ ប្រព្រឹត្តទៅក្នុងលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាពយ៉ាងពេញលេញ។ ទន្ទឹមនេះ មន្ត្រីរាជការ កងកម្លាំងនគរបាលជាតិ និងអាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវខិតខំចូលរួមអនុវត្តការងារនានាតាមសំណូមពររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងខិតខំគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ បទបញ្ជា នីតិវិធី និងក្រមសីលធម៌នៃការបោះឆ្នោត ព្រមទាំងខិតខំរួមគ្នាទប់ស្កាត់ចំពោះឧបាយកល សកម្មភាពណាមួយដែលប៉ុនប៉ងបំផ្លាញដំណើរការបោះឆ្នោតនេះ។

**ទីពីរ :** ក្រសួងមហាផ្ទៃ និងកងកម្លាំងនគរបាលជាតិ ត្រូវបន្តពង្រឹងសន្តិសុខជាតិ ដោយខិតខំបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយនគរបាលនៃប្រទេសនានាជាមិត្ត និងប្រព័ន្ធនគរបាលអន្តរជាតិ ដើរទន្ទឹមនឹងការបង្កើនកិច្ចសហការជាមួយកម្លាំងមានសមត្ថកិច្ចក្នុងផ្ទៃក្នុងប្រទេស ដើម្បី

បង្ការ ទប់ស្កាត់ឱ្យបាននូវអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ក្នុងនោះ រួមទាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មានការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណេត ដើម្បីជម្រិតទារប្រាក់ និងភ្នាល់ល្បែងខុសច្បាប់ដែលកំពុងមានស្ទើរគ្រប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍របស់យើង។ ត្រូវបន្ត សហការ បង្កាទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀន សកម្មភាពជួញដូរមនុស្សឆ្លងកាត់ព្រំដែន និងសកម្មភាពឆ្លងដែនខុសច្បាប់នានាដោយខិតខំសហការស្រាវជ្រាវបង្ក្រាបបណ្តាញមេខ្យល់ក្នុង និងក្រៅប្រទេសដែលរៀបចំខ្សែបណ្តាញអូសទាញ បោកបញ្ឆោតប្រជាពលរដ្ឋយើងឱ្យឆ្លងដែនចូលទៅធ្វើការខុសច្បាប់ក្នុងប្រទេសជិតខាងក្នុងនោះ រួមទាំងការបោកបញ្ឆោតប្រជាពលរដ្ឋយើងឱ្យចូលទៅជញ្ជូន និងកាប់ឈើខុសច្បាប់ក្នុងប្រទេសជិតខាងផងដែរ។

**ទីបី :** ទោះបីក្នុងឆ្នាំ២០១២កន្លងមក សភាពការណ៍ព្រំដែនមានការវិវត្តល្អប្រសើរ ពិសេសសភាពការណ៍តាមព្រំដែនកម្ពុជា ថៃ អាស្រ័យដោយមានការសហការល្អរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ប៉ុន្តែដូចឯកឧត្តម លោកជំទាវ លោកស្រីជ្រាបហើយថា នាពេលខាងមុខនេះ តុលាការអន្តរជាតិនឹងធ្វើការបកស្រាយសាលក្រមពាក់ព័ន្ធបញ្ហាប្រាសាទព្រះវិហារតាមបណ្តឹងរបស់ភាគីកម្ពុជា។ ក្នុងបញ្ហានេះ មាននិន្នាការមួយចំនួនបានគាបសង្កត់និងបានដាក់បញ្ហាជាច្រើន ក្នុងនោះរួមទាំងការប៉ុនប៉ងលើកយកវិធានការយោធា ដើម្បីត្រៀមក្នុងការដោះស្រាយបញ្ហាទៀតផង។ ហេតុនេះ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងនោះ រួមទាំងកងកម្លាំងនគរបាលជាតិផង ជានិច្ចកាលត្រូវតែមានការប្រុងប្រយ័ត្ន ប្រកបដោយស្មារតីម្ចាស់ការខ្ពស់ដើម្បីរួមសហការគ្នាតាមដានក្តាប់ឱ្យបានសភាពការណ៍នានា និងមានវិធានការប្រកបដោយប្រសិទ្ធភាពចំពោះរាល់សកម្មភាពអាក្រក់ណាមួយដែលយាយីមកលើបូរណភាពទឹកដី អធិបតេយ្យភាពជាតិ ក៏ដូចជាការឃោសនាសង្គ្រាមចិត្តសាស្ត្រមួលបង្កាច់កិត្តិនាមនៃព្រះរាជាណាចក្រកម្ពុជាយើង។

**ទីបួន :** លើកកម្ពស់ថែមទៀតនូវចលនាមហាជន ចូលរួមការពារសន្តិសុខ សុវត្ថិភាពនៅមូលដ្ឋាន ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈឱ្យបានកាន់តែរឹងមាំ តាមរយៈការបន្តជំរុញអនុវត្តគោលនយោបាយឃុំ ភូមិមានសុវត្ថិភាពឱ្យបានផុសផុលគ្រប់មូលដ្ឋានទូទាំងប្រទេស ដោយខិតខំធានាឱ្យបាននូវនិរន្តរភាពក្នុងការអនុវត្តគោលនយោបាយនេះ។ ទន្ទឹមនេះ កងកម្លាំងនគរបាលជាតិត្រូវបន្តកសាង ពង្រឹងសមត្ថភាព ជំនាញវិជ្ជាជីវៈ និងមនសិការវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាប បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ឱ្យមានការថយចុះថែមទៀតជាពិសេសអំពើប្លន់ ឃាតកម្ម ការជួញដូរ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស អំពើ

វិលោភ អំពើហិង្សា និងសកម្មភាពក្មេងទំនើង ដើម្បីបង្កើនភាពកក់ក្តៅថែមទៀតក្នុងជីវភាពរស់នៅ និងការប្រកបមុខរបរនានារបស់អាជីវករ និងប្រជាពលរដ្ឋគ្រប់ច្រកល្ហកទូទាំងប្រទេស ។

**ទីប្រាំ :** បន្តខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈឱ្យបានកាន់តែល្អប្រសើរ ស្របតាមការវិវត្តរីកចម្រើនរបស់ប្រទេសជាតិ ។ ក្នុងនោះបញ្ហាដែលត្រូវយកចិត្តទុកដាក់ គឺសណ្តាប់ធ្នាប់ចរាចរដែលនៅតែជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិត និងទ្រព្យសម្បត្តិប្រជាពលរដ្ឋជារៀងរាល់ថ្ងៃ ។

ចំពោះបញ្ហាអគ្គីភ័យ ខ្ញុំធ្លាប់មានមតិរួចមកហើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ នាឱកាសសម្ពោធរោងចក្រស្ករសនៅខេត្តកំពង់ស្ពឺ គឺរាជរដ្ឋាភិបាលបានលើកទឹកចិត្តដល់ផ្នែកឯកជនក្នុងការចូលរួមក្នុងចលនាបង្ការ ការពារ និងពន្លត់អគ្គីភ័យ ។ ហេតុនេះ ត្រូវយកចិត្តទុកដាក់បំផុសលើកទឹកចិត្តចលនានេះ ឱ្យមានសកម្មភាពជាក់ស្តែងថែមទៀត ។

ទន្ទឹមនេះ ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ននានា និងអាជ្ញាធរគ្រប់ថ្នាក់ ត្រូវបង្កើនការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នចំពោះបញ្ហាអគ្គីភ័យ សំដៅធានាឱ្យមានការចូលរួមពីសាធារណជន ក្នុងការបង្ការ ការពារ និងពន្លត់អគ្គីភ័យ ។ អង្គភាពជំនាញពន្លត់អគ្គីភ័យគ្រប់ថ្នាក់ ត្រូវរៀបចំឱ្យមានកម្មវិធីហាត់ ហ្វឹកហ្វឺនពន្លត់អគ្គីភ័យនៅនឹងកន្លែង ដើម្បីសង្គ្រោះបឋមដោយផ្តោតទៅលើគោលដៅសំខាន់ៗមួយចំនួនដូចជា : រោងចក្រ សហគ្រាស សិប្បកម្ម ឃ្លាំង ព្រមទាំងតំបន់ លំនៅដ្ឋានរបស់ប្រជាជនដែលមានភាពស្មុគស្មាញ ។ល ។

ការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ គឺជាការងារដ៏សាំញ៉ាំដែលមានការពាក់ព័ន្ធ ដល់វិស័យជាច្រើន និងពាក់ព័ន្ធដល់សកម្មភាពរបស់មនុស្សក្នុងសង្គមទាំងមូល ។ ហេតុនេះ ក្រសួងមហាផ្ទៃ ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានា ខិតខំចាត់វិធានការពង្រឹងការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងបន្តលើកកម្ពស់ការគ្រប់គ្រងមនុស្ស គ្រប់គ្រងអាវុធ មធ្យោបាយ ធ្វើដំណើរ និងត្រូវបន្តធ្វើការសិក្សាស្រាវជ្រាវ និងកែលម្អច្បាប់ លិខិតបទដ្ឋានដែលមានស្រាប់ និងរៀបចំច្បាប់លិខិតបទដ្ឋានថ្មីៗឱ្យបានសមស្របតាមការវិវត្តរីកចម្រើនរបស់សង្គម ។

**ទីប្រាំមួយ :** ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តភារកិច្ចខាងលើនេះ ត្រូវបន្តធ្វើការកែទម្រង់នគរបាលជាតិឱ្យបានស៊ីជម្រៅ ដោយខិតខំបង្កើនការបណ្តុះបណ្តាល កសាងសមត្ថភាពកងកម្លាំងនគរបាលនៅគ្រប់ថ្នាក់ ដើរទន្ទឹមនឹងការលើកកម្ពស់មនសិការវិជ្ជាជីវៈ ការគោរពវិន័យសីលធម៌ ដើម្បីលើកកម្ពស់គុណភាព សមត្ថភាពរបស់កងកម្លាំងនគរបាលជាតិទាំងមូល ក្នុងការផ្តល់

សេវាសន្តិសុខជូនប្រជាពលរដ្ឋឱ្យបានកាន់តែទូលំទូលាយប្រកបដោយភាពស្មោះស្ម័គ្រ រាក់ទាក់គ្រប់ទីកន្លែង និងទាន់ពេលវេលា ក្នុងឆន្ទៈ "ជួយការពារ សង្គ្រោះ និងផ្ដល់យុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់ៗរូបដោយស្មើភាព" ។ ទន្ទឹមនេះ ត្រូវរួមគ្នាធ្វើការប្ដេជ្ញាចិត្តឱ្យបានមោះមុតក្នុងការកាត់បន្ថយ និងឈានទៅលុបបំបាត់ភាពអសកម្មនានាក្នុងកងកម្លាំងនគរបាលជាតិ ។

**ទីប្រាំពីរ :** បន្តជំរុញកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបន្តបោះជំហានទៅមុខប្រកបដោយចីរភាព ស្របតាមបទប្បញ្ញត្តិនៃច្បាប់រៀបចំអង្គការ កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូងនៃកម្មវិធីជាតិនេះ ។ ក្នុងបណ្ដាឆ្នាំកន្លងទៅ ទោះបីកំណែទម្រង់នេះ សម្រេចបានសមិទ្ធផលមួយចំនួនគួរឱ្យកត់សម្គាល់ក៏ពិតមែន ប៉ុន្ដែនោះគ្រាន់តែជាដំណាក់កាលចាប់ផ្ដើមតែប៉ុណ្ណោះ ។ ពីព្រោះដំណើរការស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺការផ្ទេរមុខងារ អំណាច ធនធាន និងសមត្ថភាពទៅឱ្យរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ ដើម្បីចាត់ចែងប្រើប្រាស់មុខងារ អំណាច ធនធាន និងសមត្ថភាពទាំងនោះ សំដៅឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានឆាប់រហ័សមានតម្លាភាព គណនេយ្យភាព និងប្រកបដោយប្រសិទ្ធភាព ។

ដូច្នេះ ក្នុងឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់ឡើងវិញអំពីតម្រូវការចាំបាច់ដែលយើងទាំងអស់គ្នាត្រូវតែ ថែរក្សា និងពង្រឹងជាប្រចាំនូវការប្ដេជ្ញាចិត្តរយៈពេលវែង ក្នុងដំណើរការកំណែទម្រង់នេះ ។ ដូចឯកឧត្តម លោកជំទាវ លោកស្រី អស់លោក បានជ្រាបរួចមកហើយថា ដើម្បីរៀបចំក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់នេះ ឱ្យសមស្របជាមួយបរិបទខាងនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់កម្ពុជា ស្ថាប័នគ្រប់ថ្នាក់ ទាំងសភា រាជរដ្ឋាភិបាល ក្រសួងស្ថាប័ននានា រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ បានធ្វើការពិគ្រោះ ពិភាក្សា ហើយបានឯកភាពស្រុះស្រួលគ្នាខាងនយោបាយតាំងពីជាងមួយទសវត្សរ៍មកហើយ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ជាលើកដំបូងនាខែកុម្ភៈ ឆ្នាំ២០០២ ។ ផ្អែកលើសមិទ្ធផល និងបទពិសោធន៍ដែលទទួលបានពីកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ យើងបានឯកភាពស្រុះស្រួលគ្នាពង្រីកកំណែទម្រង់នេះនៅថ្នាក់ក្រោមជាតិទាំងមូល តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាខែឧសភា ឆ្នាំ២០០៩។ ដូចនេះ រហូតមកដល់ពេលនេះ យើងបានបង្កើតរួចហើយនូវស្ថាប័នអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានក្រុមប្រឹក្សាជាប់ឆ្នោត និងមន្ត្រីតែងតាំងនានាក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធនៃរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ។ ក្នុងបរិការនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានមុខងារ និងធនធានសមស្រប ដើម្បីអនុវត្តភារកិច្ច

នានាតាមច្បាប់តម្រូវ ។ ផ្អែកតាមកម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិនេះ ចាប់ពីឆ្នាំ២០១៣ តទៅ កំណែទម្រង់នេះ តម្រូវឱ្យមានការផ្ទេរមុខងារ ធនធាន និងសមត្ថភាពជាក់លាក់ជាជំហានៗ ទៅឱ្យរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិទាំងមូល ។

អាស្រ័យហេតុនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមរំលឹកឡើងវិញដល់ក្រសួង ស្ថាប័ននានា ត្រូវបន្តខិតខំតម្កល់ការប្តេជ្ញាចិត្តខាងនយោបាយ ដែលបានឯកភាពស្រុះស្រួលគ្នាឱ្យបានរឹងមាំ ដោយឥតងាករេ ដើម្បីរួមគ្នាបន្តជំរុញកំណែទម្រង់នេះ ឱ្យបោះជំហានចូលក្នុងដំណាក់កាលថ្មីមួយទៀត ។ ក្នុងន័យនេះ ការរៀបចំក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានរបស់ក្រសួងស្ថាប័ន នានានៅថ្នាក់ជាតិ ត្រូវតែគាំទ្រដល់ប្រព័ន្ធវិមជ្ឈការ វិសហមជ្ឈការ និងសិទ្ធិអំណាចរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ។ ដោយឡែក រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ ក៏ត្រូវតែខិតខំពង្រឹងសមត្ថភាពជា ប្រចាំ ដើម្បីប្រើប្រាស់មុខងារ អំណាច និងធនធានដែលបានផ្ទេរប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ បំផុត សំដៅឆ្លើយតបតម្រូវការនានាជាអាទិភាពរបស់មូលដ្ឋាន ។

## ទីប្រាំបី : <u>អំពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ</u> :

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងនូវការកោតសរសើរចំពោះក្រសួង ស្ថាប័ននានា ដែលបាន រួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការកំណត់ កំរៃសេវា ដើម្បីរួមគ្នាលុបបំបាត់ការយកកំរៃសេវាមិនស្របច្បាប់នានា ។ ប៉ុន្តែដោយសារការកំណត់ កំរៃសេវារបស់ក្រសួង ស្ថាប័ននានា មានផលប៉ះពាល់មកលើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហេតុនេះក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ បានពិគ្រោះ ពិភាក្សាគ្នាស្នើសុំរាជរដ្ឋាភិបាល ពិសេសរូបខ្ញុំផ្ទាល់ ក្នុងឋានៈជានាយករដ្ឋមន្ត្រី ដើម្បីធ្វើការដឹកនាំ ណែនាំ តម្រង់ទិសដំណើរការនេះ ភ្ជាប់ជាមួយកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈ ការពង្រឹងរដ្ឋបាល ឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ការចូលរួម និងការទទួលខុសត្រូវរបស់រដ្ឋបាល គ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ក្នុងដំណើរការផ្តល់សេវារដ្ឋបាល និងការលុបបំបាត់ការយកកំរៃសេវាមិន ស្របច្បាប់នានា តាមរយៈការដាក់ចេញអនុក្រឹត្យស្តីពីការផ្តល់សេវា រដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានផ្សព្វផ្សាយនៅក្នុងសន្និបាតនេះ ។

ក្នុងឱកាសនេះ ខ្ញុំសូមធ្វើការគូសបញ្ជាក់ឡើងវិញដល់ក្រសួង ស្ថាប័ននានា អំពីតម្រូវការចាំបាច់ ក្នុងការចូលរួមគាំទ្រគោលនយោបាយកំណែទម្រង់នេះ ដើម្បីរួមគ្នាកសាងពង្រឹងរដ្ឋបាលឯកភាពនៅ ថ្នាក់ក្រោមជាតិ ។ ក្នុងន័យនេះ រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ គឺជារដ្ឋបាលសាធារណៈរបស់គ្រប់ ក្រសួង ស្ថាប័ន មិនមែនជាខ្សែបណ្តោយរបស់ក្រសួងមហាផ្ទៃតែមួយនោះឡើយ ។ តាមច្បាប់រៀបចំ

អង្គការ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល នៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ហេតុនេះ ការផ្ទេរ ឬការធ្វើប្រតិភូកម្ម មុខងារ អំណាច ធនធាន ពីក្រសួង ស្ថាប័ននានា ត្រូវផ្ទេរ ឬប្រតិភូកម្មទៅឱ្យរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ មិនមែនជាការផ្ទេរត្រង់ទៅមន្ទីរ អង្គភាពជំនាញ ខ្សែបណ្តោយរបស់ខ្លួននោះឡើយ។ ប្រព័ន្ធនេះ មិនមានន័យថា ជាការលុបបំបាត់តួនាទីរបស់មន្ទីរ អង្គភាព ជំនាញខ្សែបណ្តោយនោះឡើយ។ មន្ទីរជំនាញនានា នៅតែធ្វើជាសេនាធិការលើការងារជំនាញរបស់ខ្លួន ជូនក្រុមប្រឹក្សា និងគណៈអភិបាលនៅតាមថ្នាក់រដ្ឋបាលនីមួយៗដដែល។ នេះជាមធ្យោបាយ ដើម្បីបង្កិតសេវា ទាំងសេវារដ្ឋបាល និងសេវាសាធារណៈនានាទៅជិតប្រជាពលរដ្ឋ។ ក្នុងការអនុវត្តមុខងារដែលបានទទួលពីថ្នាក់ជាតិ ក្រុមប្រឹក្សា និងគណៈអភិបាល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតែទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ក៏ដូចក្រសួង ស្ថាប័ននានា និងប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ទីប្រាំបួន :** ទន្ទឹមនឹងនេះ រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ត្រូវបន្តចូលរួមទទួលខុសត្រូវក្នុងការអនុវត្តឱ្យបានកាន់តែសកម្មថែមទៀតនូវ "គោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី" ឱ្យសម្រេចបានតាមផែនការដែលបានកំណត់ និងត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទបញ្ជារបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ឡូតិ៍នេសាទ ដោយខិតខំធ្វើការបង្ក្រាបឱ្យបានដាច់ខាតនូវបទល្មើសនេសាទខុសច្បាប់ ក៏ដូចជាការកាប់បំផ្លាញព្រៃលិចទឹក សំដៅរួមគ្នាការពារធនធានមច្ឆាជាតិ សម្រាប់ជាផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងសង្គមរបស់យើង។ ម្យ៉ាងទៀត ត្រូវយកចិត្តទុកដាក់លុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យក្នុងដែនសមត្ថកិច្ចនៃថ្នាក់រដ្ឋបាលនីមួយៗឱ្យបានព្រមៗគ្នាក្នុងទូទាំងប្រទេស តាមរយៈការចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពនូវយន្តការដែលបានបង្កើតរួចហើយ។ ទន្ទឹមនេះ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើនកិច្ចសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង សមត្ថកិច្ចពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីបន្តដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ ប្រកបដោយប្រសិទ្ធភាព សំដៅលើកកម្ពស់សុវត្ថិភាព និងគុណភាពជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ខាងលើនេះ ជាអនុសាសន៍សំខាន់ៗមួយចំនួន សំដៅបំពេញបន្ថែមទៅលើវិធានការនានាដែលអង្គសន្និបាតទាំងមូលបានពិភាក្សាឯកភាពគ្នាក្នុងទិសដៅអនុវត្តក្នុងឆ្នាំ២០១៣នេះ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងមហាផ្ទៃ ទាំងរដ្ឋបាលស៊ីវិលនឹងនគរបាលជាតិ ក៏ដូចរដ្ឋបាលថ្នាក់ក្រោមជាតិ

នឹងបន្តរួមសាមគ្គីសហការគ្នាជាធ្លុងមួយ ដើម្បីអនុវត្តសម្រេចឱ្យបាននូវអនុសាសន៍របស់ខ្ញុំ និងទិសដៅការងារឆ្នាំ២០១៣ សំដៅរួមចំណែកធានាឱ្យរាជរដ្ឋាភិបាលសម្រេចដោយជោគជ័យនូវទិសដៅ ភារកិច្ចសំខាន់ៗក្នុងឆ្នាំ២០១៣ ក៏ដូចជាការសម្រេចបានដោយជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ ដើម្បីបន្តជំរុញឱ្យប្រទេសជាតិរបស់យើងមានការវិវត្តរីកចម្រើនលើគ្រប់វិស័យ ប្រកបដោយចីរភាព និងវិបុលភាព ។

ចុងបញ្ចប់នេះ ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសបិទសន្និបាតបូកសរុបការងារឆ្នាំ២០១២ និងលើកទិសដៅការងារឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃចាប់ពីពេលនេះ និងសូមប្រសិទ្ធពរជ័យជូនគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកជាភ្ញៀវកិត្តិយស និងសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល សូមប្រកបដោយពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**